# PRESS ADVISORY

សេចក្តីប្រកាសព័ត៌មាន
ថ្ងៃទី25 ខែសីហា ឆ្នាំ2020

**ទំនាក់ទំនង៖**
**Sylvia Soublet**
ទីភ្នាក់ងារសេវាសង្គម នាយកកិច្ចការសាធារណៈ
O: (510) 267-9434 / C: (510) 207-2074
F: (510) 271-9120
ssoublet@acgov.org

## ខោនធី **Alameda** អនុវត្តកម្មវិធីស្តារសេដ្ឋកិច្ចដើម្បីដោះស្រាយវិបត្តិសុខភាពសាធារណៈ ជំងឺកូវីដ **19**
## ទំនួលខុសត្រូវខោនធី **Alameda** ចំពោះសុខភាពសហគមន៍ **(ARCH)**
## មានគោលបំណងជួយទប់ស្កាត់ការរីករាលដាលវីរុសដោយសម្របសម្រួលការដាក់ខ្លួននៅដាច់ដោយឡែកពីអ្នកដទៃ

Oakland, CA – ទីភ្នាក់ងារសេវាសង្គមខោនធី Alameda (ACSSA) ដោយបានសហការជាមួយសេវាថែទាំសុខភាពរបស់ខោនធី (HCSA) និងទីភ្នាក់ងារសវនករ/អ្នកត្រួតពិនិត្យបានដាក់ឱ្យអនុវត្តកម្មវិធីស្តារសេដ្ឋកិច្ចកាលពីថ្ងៃទី24 ខែសីហា ឆ្នាំ2020 ដើម្បីដោះស្រាយវិបត្តិសុខភាពសាធារណៈជំងឺកូវីដ 19។ ទំនួលខុសត្រូវខោនធី Alameda ចំពោះសុខភាពសហគមន៍ ឬ ARCH ដែលពីមុនហៅថាកម្មវិធីផ្តល់ប្រាក់ឧបត្ថម្ភសាកល្បង (Pilot Stipend Program) មានគោលបំណងទប់ស្កាត់ការរីករាលដាលវីរុសកូវីដ 19 នៅខោនធី Alameda តាមរយៈការផ្តល់ជំនួយហិរញ្ញវត្ថុសម្រាប់ពលរដ្ឋខោនធីដែលដាក់ខ្លួននៅដាច់ដោយឡែកពីអ្នកដទៃដែលបានធ្វើតេស្តរកឃើញមានជំងឺកូវីដ 19។ ការផ្តល់មូលនិធិ និងការរៀបចំកម្មវិធីសាកល្បងត្រូវបានអនុម័តជាឯកច្ឆ័នដោយក្រុមប្រឹក្សាអ្នកគ្រប់គ្រង ខោនធី Alameda កាលពីថ្ងៃទី04 ខែសីហា ឆ្នាំ2020។

"សហគមន៍របស់យើងបានប្រាប់យើងថា ពួកគាត់ត្រូវធ្វើសេចក្តីសម្រេចចិត្តដ៏លំបាករវាងការនៅដាច់ដោយឡែក និងការបាត់បង់ប្រាក់ខែត្រូវការចាំបាច់ចំនួនពីរសប្តាហ៍ប្រសិនបើខ្លួនត្រូវបានធ្វើតេស្តរកឃើញមានជំងឺកូវីដ 19។ Wilma Chan ដែលជាអ្នកគ្រប់គ្រង ខោនធី Alameda បានលើកឡើងថា ពុំគួរមាននរណាម្នាក់ជ្រើសរើសជម្រើសនេះឡើយ។ "កម្មវិធីនេះនឹងផ្តល់លទ្ធភាពឱ្យបុគ្គលមានជំងឺកូវីដ 19 នៅក្នុងតំបន់ដែលរងការប៉ះពាល់ខ្លាំងជាងគេរបស់យើងអាចរក្សាបាននូវស្ថិរភាពហិរញ្ញវត្ថុ ខណៈការពារសហគមន៍របស់គាត់មិនឱ្យមានការរីករាលដាលជំងឺជាបន្តទៀត"។

ទីភ្នាក់ងារសេវាសង្គមខោនធី Alameda រួមជាមួយនឹងទីភ្នាក់ងារសេវាថែទាំសុខភាព ទីភ្នាក់ងារសវនករ/អ្នកត្រួតពិនិត្យ និងដៃគូគ្លីនិកសុខភាពតាមសហគមន៍ដែលបានជ្រើសរើស បានអនុវត្តកម្មវិធី ARCH ដើម្បីចាប់ផ្តើមផ្តល់សេវាភ្លាមៗដល់ពលរដ្ឋខោនធីដែលអាចមានសិទ្ធិទទួល។ ARCH នឹងចែកចាយទឹកប្រាក់ប្រមាណ 10 លានដុល្លារ ជាជំនួយសេដ្ឋកិច្ចដល់ពលរដ្ឋខោនធីប្រមាណ 7,500 នាក់ដែលដោយសារតែអស្ថិរភាពផ្នែកសេដ្ឋកិច្ច អាចនៅបន្តធ្វើការបន្ទាប់ពីធ្វើតេស្តឃើញមានជំងឺកូវីដ 19។

Susan Muranishi ដែលជាអ្នកគ្រប់គ្រង ខោនធី Alameda បានលើកឡើងថា "ការសាកល្បងគឺដើម្បីផ្តល់ទឹកប្រាក់ឧបត្ថម្ភដល់បុគ្គលនិងគ្រួសារដែលត្រូវដាក់ខ្លួននៅដាច់ដោយឡែកនៅពេលនេះដើម្បីសុខភាព និងសុវត្ថិភាពផ្ទាល់ខ្លួនរបស់ពួកគាត់ និងសហគមន៍"។ "ខោនធីយល់ឃើញថា ការផ្តល់ជម្រកនៅនឹងកន្លែង ខណៈធ្វើរោគវិនិច្ឆ័យមានជំងឺកូវីដ 19 មិនគួរជាបុព្វសិទ្ធិសម្រាប់តែអ្នកដែលអាចមានលទ្ធភាពទិញឡើយ"។

កម្មវិធី ARCH កំណត់គោលដៅពលរដ្ឋមានជំងឺកូវីដ 19 ដែលរស់នៅក្នុងតំបន់មានហានិភ័យខ្ពស់ដែលបានកំណត់ ដែលរួមមាន៖ South Hayward, Ashland/Cherryland, East Oakland, West Oakland, និង Fruitvale/San Antonio។

Lori Cox ដែលជានាយកភ្នាក់ងារសេវាសង្គមខោនធី Alameda បានពន្យល់ថា "ក្នុងនាមជាខោនធីមួយ យើងជឿជាក់យ៉ាងមុតមាំថា ពុំគួរមាននរណាម្នាក់ត្រូវជ្រើសរើសរវាងការធ្វើអ្វីដែលត្រឹមត្រូវដើម្បីសុខភាពខ្លួនឯង និងសហគមន៍របស់ខ្លួន និងការចិញ្ចឹមខ្លួនឯង ឬគ្រួសាររបស់ខ្លួនឡើយ"។ "ពេលវេលាពិសេសទាំងនេះតម្រូវមានវិធានការ និងកិច្ចខិតខំប្រឹងប្រែងពិសេស។ អ្នកទាំងអស់គ្នាដែលធ្វើការក្នុងកម្មវិធី ARCH មានការប្តេជ្ញាចិត្តខ្ពស់ និងខិតខំអស់កម្លាំងកាយចិត្តដើម្បីធ្វើឱ្យកម្មវិធីនេះទទួលបានលទ្ធផលល្អ"។

យើងជឿជាក់ថា ពលរដ្ឋខោធីដែលមានសិទ្ធិជាច្រើន អាចជាបុគ្គលិកដែលមានសារសំខាន់ដែលមិនអាចធ្វើការពីចម្ងាយបានទេ ដូច្នេះ

កត្តានេះធ្វើឱ្យពួកគាត់ប្រឈមនឹងហានិភ័យខ្ពស់ពីការឆ្លងជំងឺកូវីដ 19។ ពលរដ្ឋងាយរងគ្រោះដែលធ្វើតេស្តរកឃើញមានជំងឺកូវីដ 19 នឹងត្រូវភ្ជាប់ទៅកាន់កម្មវិធីតាមរយៈបណ្ដាញអ្នកផ្តល់សេវាវេជ្ជសាស្ត្រសហគមន៍របស់ HCSA នៃសេវាស្រាវជ្រាវករណី/តាមដានការប៉ះពាល់តាមសហគមន៍ (Community-Based Case Investigation/Contact Tracing)។

Colleen Chawla ដែលជានាយកទីភ្នាក់ងារសេវាថែទាំសុខភាពខោនធី Alameda បានថ្លែងថា “កម្មវិធីនេះនឹងជួយយើងនៅក្នុងការកាត់បន្ថយការរាលដាលជំងឺកូវីដ 19 តាមរយៈការផ្តល់ជំនួយហិរញ្ញវត្ថុដល់ពលរដ្ឋផ្ទុកជំងឺដែលពុំមានមធ្យោបាយក្នុងការដាក់ខ្លួននៅដាច់ដោយឡែកដោយសុវត្ថិភាព”។ “ពលរដ្ឋទាំងនេះរួមមាន ក្រុមបុគ្គលិកសំខាន់ដែលមិនអាចធ្វើការពីចម្ងាយ និងបុគ្គលិកធ្វើការគិតម៉ោងដែលមិនអាចបាត់បង់ប្រាក់ឈ្នួលរបស់ខ្លួនបាន”។

គ្លីនិកសុខភាពដែលបានចូលរួម រួមជាមួយនឹងនាយកដ្ឋានសុខភាពសាធារណៈខោនធី Alameda នឹងផ្តោតទៅលើការថែទាំសុខភាព៖ ការធ្វើតេស្តរកជំងឺកូវីដ 19 លទ្ធផល និងការបញ្ជូនបន្តតែប៉ុណ្ណោះ។
គ្លីនិកសុខភាពនឹងពុំមានតួនាទីនៅក្នុងដំណើរការចែកចាយប្រាក់ឧបត្ថម្ភឡើយ។
Noha Aboelata ដែលជាមន្ត្រីប្រតិបត្តិ MD នៃមណ្ឌលសុខភាពសហគមន៍ បានលើកឡើងថា
“បុគ្គលសំខាន់ជាច្រើនកំពុងប្រឈមនឹងជម្រើសមិនអាចទៅរួចនៅពេលពួកគាត់មានជំងឺកូវីដ 19៖
បាត់បង់ប្រាក់ចំណូលជាច្រើនសប្តាហ៍ ឬក៏ប្រឈមនឹងបទបញ្ហាសុខភាពសាធារណៈ”។
“យើងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះថ្នាក់ដឹកនាំខោនធី Alameda ដែលបានលុបបំបាត់យ៉ាងមាន
ប្រសិទ្ធភាពនូវឧបសគ្គនៃការបាត់បង់ប្រាក់ចំណូល ការពារកម្មករនិយោជិតទាំងនេះ គ្រួសាររបស់ពួកគាត់ និងសហគមន៍ទូទៅ”។

កម្មវិធី ARCH នឹងផ្តល់ប្រាក់ឧបត្ថម្ភមួយដងចំនួន $1,250.00 ជាប័ណ្ណសាច់ប្រាក់ VISA តាមរយៈភាពជាដៃគូជាមួយសហភាពឥណទាន First United Services Credit Union។ ជំនួយនឹងមិនលើសពីចំនួន 14 ថ្ងៃឡើយ។ ខោនធីធ្វើការបញ្ជាក់យ៉ាងច្បាស់លាស់ថា ស្ថានភាពអន្តោប្រវេសន៍របស់អ្នកដាក់ពាក្យស្នើសុំនឹងមិនប៉ះពាល់ដល់សិទ្ធិទទួលបានអត្ថប្រយោជន៍ពីកម្មវិធីឡើយ។
សមាសភាពកម្មវិធីសំខាន់ៗផ្សេងៗទៀតបញ្ជាក់ថា អ្នកដាក់ពាក្យសុំមិនអាចស្ថិតក្នុងស្ថានភាពកំពុង
ទទួលបានអត្ថប្រយោជន៍ធានារ៉ាប់រងគ្មានការងារធ្វើ ឬការឈប់សម្រាកដោយមានប្រាក់ឈ្នួលឡើយ។

Ralph Silber ដែលជានាយកប្រតិបត្តិនៃសហគមន៍សុខាភិបាល Alameda Health Consortium បានលើកឡើងថា “ខោនធី Alameda កំពុងធ្វើកិច្ចការត្រឹមត្រូវ តាមរយៈការផ្តល់ជំនួយដល់ពលរដ្ឋប្រាក់ចំណូលទាបដែលមានជំងឺ 19 ដើម្បីឱ្យពួកគាត់អាចសម្រាកពីការងារដើម្បីនៅផ្ទះ និងទប់ស្កាត់ការរីករាលដាលជំងឺនេះ”។
“កម្មវិធីនេះនឹងជួយមណ្ឌលសុខភាពសហគមន៍របស់យើងក្នុងការ
គាំទ្រសហគមន៍របស់យើងដែលរងការប៉ះពាល់ដោយសារជំងឺរាតត្បាតខ្លាំងជាងគេ”។

បញ្ជីសំណួរចម្លើយទូទៅ (FAQ) មួយចំនួននឹងមាននៅលើវេបសាយត៍ www.acgov.org និងវេបសាយត៍ ACSSA៖ www.alamedasocialservices.org. សាធារណជនគួរបើកមើលបញ្ជីសំណួរចម្លើយទូទៅឱ្យបានញឹកញាប់។

សម្រាប់ទិន្នន័យអំពីជំងឺកូវីដ 19 ខោនធី Alameda ថ្មីចុងក្រោយ សូមមើលវេបសាយត៍របស់នាយកដ្ឋានសុខភាពសាធារណៈខោនធី Alameda៖ http://www.acphd.org/